THE SCHOOL DISTRICT OF
PHILADELPHIA

**OFFICE OF THE SUPERINTENDENT**
440 North Broad Street
Philadelphia, PA 19130

**William R. Hite, Jr., Ed.D.**
Superintendent

ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០២២

ជូនចំពោះ មាតាបិតា និងក្រុមគ្រួសារ របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

ខ្ញុំសរសេរលិខិតថ្ងៃនេះ ដើម្បីចែករំលែក ប្រតិទិនសម្រាប់ការសិក្សា ក្នុងឆ្នាំសិក្សា ២០២២-២០២៣ ដែលបានអនុម័តដោយក្រុមប្រឹក្សាអប់រំកាលពីយប់មិញ និងអញ្ជើញលោកអ្នកឱ្យចែករំលែកនូវគំនិត និងយោបល់សំខាន់ៗមួយចំនួនរបស់លោកអ្នកក្នុងការស្ទង់មតិ ដែលនឹងជួយឱ្យយើងដឹងក្នុងការសម្រេចចិត្តរបស់យើងក្នុងពេលប៉ុន្មានខែខាងមុខនេះ។

**ប្រតិទិនសម្រាប់ការសិក្សា ក្នុងឆ្នាំសិក្សា ២០២២-២២២០២៣**

ឆ្នាំនេះ យើងបានចំណាយពេលបន្ថែមដើម្បីបង្កើតប្រតិទិនដែលត្រូវតាមតម្រូវការរបស់រដ្ឋ និងតំបន់ទាំងអស់ ហើយផ្តល់ម៉ោងបន្ថែមដែលអ្នកអប់រំរបស់យើងត្រូវការដើម្បីចូលរួមក្នុងការហ្វឹកហ្វឺនវិជ្ជាជីវៈ ពង្រឹងការអនុវត្តនៃការបង្ហាត់បង្រៀនរបស់ពួកគេ និងពន្លឿនការសិក្សារបស់សិស្សឱ្យស្របតាម គោលដៅ និងការគាំទ្រ របស់ក្រុមប្រឹក្សាភិបាល (Board’s Goals and Guardrails)។ **ថ្ងៃចូលរៀនដំបូងសម្រាប់សិស្ស ថ្នាក់មុនមត្តេយ្យ ដល់ ថ្នាក់ទី ១២ គឺនៅថ្ងៃ ច័ន្ទ ទី ២៩ ខែ សីហា ឆ្នាំ ២០២២** ដែលសិស្សថ្នាក់មត្តេយ្យចេញមុនបីម៉ោង។

នៅចុងនិទាឃរដូវនេះ ជាផ្នែកមួយនៃការប្តេជ្ញាចិត្តរបស់យើងក្នុងការធ្វើឱ្យកាន់តែមានការចូលរួមរបស់យើងជាមួយក្រុមគ្រួសាររបស់យើងក្នុងវិធីអភិវឌ្ឍប្រតិទិន លោកអ្នកនឹងត្រូវបានអញ្ជើញឱ្យចូលរួមជាមួយយើងសម្រាប់ការសន្ទនាដើម្បីជួយផ្តល់ដំណឹងអំពីប្រតិទិនសម្រាប់ការសិក្សាក្នុងឆ្នាំសិក្សា ២០២៣-២០២៤ និង ២០២៤-២០២៥។ សូមរង់ចាំព័ត៌មានបន្ថែមអំពីកិច្ចប្រជុំនាពេលខាងមុខ។

***មានឥឡូវនេះ!* ការចូលរួមក្នុងការស្ទង់មតិអំពីថវិកាឆ្នាំ ២០២២!**

ឆ្នាំសិក្សានេះ យើងបានបណ្តាក់ទុនរាប់រយលានដុល្លារបន្ថែមទៀតនៃជំនួយសហព័ន្ធដែលបានពី ច្បាប់ផែនការសង្គ្រោះអាមេរិកាំង [American Rescue Plan Act (ARPA)] ដើម្បីធ្វើការវិនិយោគសំខាន់ៗទៅលើសាលា និងសិស្ស របស់យើង។ ការវិនិយោគទាំងនេះ បានផ្តល់យោបល់ដោយលោកអ្នកតាមរយៈនៃការចូលរួមក្នុងការស្ទង់មតិអំពីថវិកា កាលពីឆ្នាំមុន ដែលត្រូវបានគាំទ្រ៖ ឱ្យមាន កម្មវិធី មុន និង

ក្រោយ ម៉ោងរៀន ឱ្យកាន់តែច្រើននៅក្នុងសាលា។ ឱ្យមាន អ្នកចិត្តសាស្ត្រ អ្នកបង្ហាត់បង្រៀនអំពីសកម្មភាពប្រចាំថ្ងៃដល់សិស្សពិការអ្វីមួយ និងអ្នកបង្ហាត់បង្រៀនខាងការនិយាយ ដែលជួយសិស្សឱ្យកាន់តែច្រើនថែមទៀត។ ឱ្យមាន អ្នកប្រឹក្សាផ្នែកសុខភាពផ្លូវចិត្ត និងអ្នកឯកទេសក្នុងឆ្លើយតបទៅនឹងសន្តិសុខ និងការប៉ះទង្គិចធ្ងន់ធ្ងរអ្វីមួយនៅសាលា ឱ្យកាន់តែច្រើន និងកម្មវិធីសិក្សានៅរដូវក្តៅដែលបង្កើនចំណេះដឹង។ **ឥឡូវនេះយើងខ្ញុំសូមអញ្ជើញលោកអ្នកឱ្យចូលរួមក្នុងការស្ទង់មតិអំពីថវិកា ឆ្នាំ ២០២២ ដើម្បីជួយផ្តល់យោបល់អំពីការវិនិយោគបន្ទាប់របស់យើង** សម្រាប់ឆ្នាំសិក្សាខាងមុខនេះ។ លោកអ្នកអាចចូលរួមការស្ទង់មតិតាមអ៊ិនធ័រណិត ដែលចំណាយពេល ១០ នាទី ដោយចុច ត្រង់នេះ ពីថ្ងៃនេះ រហូតដល់ ថ្ងៃទី ៨ ខែ មេសា - ដែលមានជាច្រើនភាសា។ លោកអ្នកក៏អាចមើលលទ្ធផលនៃការការស្ទង់មតិកាលពីឆ្នាំមុន នៅត្រង់នេះ ផងដែរ។

***នឹងមានក្នុងពេលឆាប់ៗនេះ!* ការស្ទង់មតិអំពីសំណើ កាលវិភាគសាលា (Bell Schedule)**

ដូចដែលយើងបានប្រកាសកាលពីសប្តាហ៍មុន ចាប់ផ្តើមនៅរដូវស្លឹកឈើជ្រុះនេះ វិទ្យាល័យទាំងអស់របស់ក្រសួងអប់រំ នឹងប្តូរទៅចាប់ផ្តើមនៅម៉ោង ៩:00 ព្រឹក លើកលែងតែសាលាបួន ដែលកាលវិភាគត្រូវតែស្របតាមស្ថាប័នដៃគូ–រួមទាំងវិទ្យាល័យដែលរួមបញ្ចូលអនុវិទ្យាល័យ។ នៅថ្ងៃ ច័ន្ទ ទី ២៨ ខែ មីនា យើងនឹងចាប់ផ្តើមការស្ទង់មតិតាមអ៊ិនធ័រណិតខ្លីមួយ ដោយអញ្ជើញ មាតាបិតា និងអាណាព្យាបាល ឱ្យផ្តល់យោបល់អំពីជំនួយដែលពួកគេត្រូវការ នៅពេលដែលពួកគេរៀបចំផែនការទុក និងកែសម្រួល ទៅតាម កាលវិភាគសាលា ថ្មីនេះ។ ចាប់ផ្តើមនៅថ្ងៃ ច័ន្ទ លោកអ្នកនឹងអាចចូលរួមក្នុងការស្ទង់មតិ ដោយចុច ត្រង់នេះ ។

សូមអរគុណចំពោះភាពជាដៃគូរបស់អ្នក។

ដោយសេចក្តីស្មោះស្ម័គ្រ



William R. Hite Jr., Ed.D.
អគ្គនាយកក្រសួងអប់រំ
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា